២០១៩ ការប្រកួតសំណេរ

*ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០*

# "តើកម្ពុជាត្រូវត្រៀមខ្លួនដូចម្តេច សម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤?"

ទាវ រដ្ឋា*
ជ័យលាភីលេខ៣ ការប្រកួតសំណេរឆ្នាំ២០១៩

**សេចក្តីសង្ខេប៖** រាជរដ្ឋាភិបាលកម្ពុជាបានត្រៀមខ្លួនក្នុងការទទួលយកបដិវត្តន៍ឧស្សាហកម្មទី៤ ដោយដាក់ចេញនូវយុទ្ធសាស្ត្រតាមក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងការអភិវឌ្ឍធនធានមនុស្ស បំពាក់គ្រឿងអេឡិចត្រូនិកតាមគ្រឹះស្ថានសិក្សានានា បណ្តុះបណ្តាលគ្រូបង្គោលនិងអ្នកជំនាញ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យគ្រឹះស្ថានសិក្សាឯកជន ក្នុងការបញ្ចូលកម្មវិធីសិក្សាទាក់ទងនឹងបច្ចេកវិទ្យាឌីជីថល។ ជាក់ស្តែងការយល់ដឹងទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យា និងសម្ភារអេឡិចត្រូនិកនានាក្នុងកម្ពុជានៅមានកម្រិតនៅឡើយ ដែលជាបញ្ហាប្រឈមមួយសម្រាប់កម្ពុជា។ ការចាប់យកបដិវត្តន៍ឧស្សាហកម្មទី៤ ជាកត្តាមួយសំខាន់ ដែលនឹងជួយឱ្យកម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យ និងអាចក្លាយជាប្រទេសដែលមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ ក្នុងន័យនេះ កម្ពុជាបានត្រៀមលក្ខណៈមួយចំនួនដូចជា ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងធនធានហិរញ្ញវត្ថុ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា កាលានុវត្តភាព និងដាក់ចេញនូវយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយបញ្ហាប្រឈមឱ្យកាន់តែប្រសិទ្ធភាព និងទាញយកគុណប្រយោជន៍ជាអតិបរមាពីបដិវត្តន៍ឧស្សាហកម្មទី៤ ប៉ុន្តែដើម្បីសម្រេចនូវកិច្ចការទាំងអស់នេះទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់រូបទូទាំងប្រទេស។

## សេចក្តីផ្តើម

បដិវត្តន៍ឧស្សាហកម្មទី៤ គឺជាបដិវត្តន៍ថ្មីនៃយុគសម័យឌីជីថលដែលកំពុងក្លាយជាប្រធានបទមួយពេញនិយមមួយក្នុងចំណោមថ្នាក់ដឹកនាំទូទាំងពិភពលោក អ្នកសិក្សាស្រាវជ្រាវ អ្នកជំនាញក៏ដូចជាអ្នកបង្កើតគោលនយោបាយជាដើម។ ក្នុងបរិបទកម្ពុជាវិញ រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់លើបដិវត្តន៍ឧស្សាហកម្មទី៤ ដោយបានរៀបចំជាវេទិកាជជែកវែកញែកទាក់ទងនឹងប្រធានបទថ្មីនេះ និងដាក់ចេញនូវយុទ្ធសាស្ត្រផែនការដើម្បីសម្របខ្លួនទៅនឹងទំនើបកម្មថ្មីនេះ។ បដិវត្តន៍ឧស្សាហកម្មទី៤ សំដៅលើការអភិវឌ្ឍបច្ចេកវិទ្យាជឿនលឿនមួយចំនួនដូចជា ការបោះពុម្ព 3D បច្ចេកវិទ្យាមនុស្សយន្ត បច្ចេកវិទ្យាជីវសាស្ត្រ Quantum Computing នំនើបកម្មលើបណ្តាញទូរគមនាគមន៍ និងចំណេះដឹងធ្វើថ្មីៗអំពីការគ្រប់គ្រងផលិតកម្ម ដែលកំពុងអភិវឌ្ឍខ្លួនបន្តពីបដិវត្តន៍ឧស្សាហកម្មទី៣។ បច្ចុប្បន្ន នវានុវត្តន៍នៃបច្ចេកវិទ្យាថ្មីៗទាំងនោះ បានធ្វើឱ្យបដិវត្តន៍ឧស្សាហកម្មទី៤ កាន់តែមានឥទ្ធិពល ដែលវានឹងមានវិសាលភាពទូលំទូលាយជាងបដិវត្តន៍ឧស្សាហកម្មជំនាន់មុនៗទាំងអស់។ បដិវត្តន៍ឧស្សាហកម្មទី៤ នឹងប្រាបាច់បញ្ចូលគ្នារវាងពិភពរូបសាស្ត្រ ពិភពឌីជីថល និងពិភពជីវសាស្ត្រ ដែលអាចផ្តល់កាលានុវត្តភាពការងារកាន់តែច្រើន និងអត្ថប្រយោជន៍យ៉ាងលើសលប់។ ដូចនេះដើម្បីឆ្លើយតបទៅនឹងការរីកលូតលាស់នៃបដិវត្តន៍ឧស្សាហកម្មទី៤ កម្ពុជាបានត្រៀមលក្ខណៈមួយចំនួន ដូចជាការពង្រឹងនូវសក្តានុភាពវិស័យអប់រំ និងការបន្តជំរុញការអភិវឌ្ឍធនធានមនុស្សប្រកប

*__ទាវ រដ្ឋា__ ជានិស្សិតឆ្នាំទី៣ ជំនាញរដ្ឋបាលសាធារណៈនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

ដោយសមត្ថភាព គុណភាព និងជំនាញពិតប្រាកដដែលអាចប្រកួតប្រជែងលើឆាកតំបន់ និងអន្តរជាតិ។ លើសពីនេះ កម្ពុជាត្រូវមានស្នូលរឹងមាំផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា និងមានធនធានហិរញ្ញវត្ថុមួយដ៏រឹងមាំដើម្បីជាកាតាលីករក្នុងការជំរុញដំណើរការបែបឌីជីថល។ សំខាន់ជាងនេះ កម្ពុជាក៏ត្រូវរៀបចំយុទ្ធសាស្ត្រនានាប្រកបដោយប្រសិទ្ធិភាព ដើម្បីទាញយកនូវផលប្រយោជន៍ និងឆ្លើយតបទៅនឹងការគំរាមកំហែង ឬបញ្ហាប្រឈមនានាដែលអាចកើតមានឡើង។

## តើកម្ពុជាគួរត្រៀមខ្លួនដូចម្ដេចសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤?

វិសាលភាពបដិវត្តន៍ឧស្សាហកម្មទី៤ នឹងស្ថិតនៅក្នុងកម្រិតមួយទូលំទូលាយជាងបដិវត្តន៍ឧស្សាហកម្មមុនៗ ជាពិសេសវានឹងធ្វើឱ្យជីវិតរស់នៅរបស់មនុស្សជាតិកាន់តែមានភាពងាយស្រួល និងជួយអភិវឌ្ឍប្រទេសឱ្យមានការផ្លាស់ប្ដូរលឿនបំផុត។ ដូចនេះទើបបដិវត្តន៍ឧស្សាហកម្មទី៤ បានក្លាយជាប្រធានបទមួយដែលទទួលបានការចាប់អារម្មណ៍ និងមានបណ្ដាប្រទេសជាច្រើនបានត្រៀមលក្ខណៈសម្រាប់ទទួលយកបដិវត្តន៍ឧស្សាហកម្មទី៤។ ជាក់ស្ដែង កម្ពុជាបានត្រៀមខ្លួនក្នុងការអភិវឌ្ឍធនធានមនុស្ស អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ពង្រឹងធនធានហិរញ្ញវត្ថុ ត្រៀមនូវគោលនយោបាយនានា និងប្រមើលមើលពីភាពវិជ្ជមាន និងភាពអវិជ្ជមាន ដែលកើតមានក្នុងបដិវត្តន៍ឧស្សាហកម្មទី៤។

- ❖ **ការអភិវឌ្ឍធនធានមនុស្ស**

ធនធានមនុស្សជាកត្តាចម្បង ដែលប្រទេសជុំវិញពិភពលោកចាប់អារម្មណ៍ និងព្រួយបារម្ភ។ ជាក់ស្ដែង សាស្ត្រាចារ្យជនជាតិអាហ្វ្រិកម្នាក់បានសរសេរថា "បើចង់ឱ្យជាតិសាសន៍មួយដួលរលំ គេមិនចាំបាច់ប្រើអាវុធបរមាណូ ឬ ក៏មីស៊ីលអ្វីឡើយ គឺគេគ្រាន់តែបន្ថយគុណភាពការអប់រំ" (RattanakSar87, ឆ្នាំ ២០១៩)។ ដូចនេះ វិស័យអប់រំជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យដទៃទៀត ដែលជួយការត្រួសត្រាយផ្លូវកម្ពុជាលើដំណើរផ្លូវឆ្ពោះទៅកាន់បដិវត្តន៍ឧស្សហកម្មទី៤។ ក្នុងបរិបទនេះ ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ផ្ដោតសំខាន់លើការកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជា ឱ្យក្លាយជាសង្គមរីកចម្រើន ដោយផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន ("អំពីក្រសួងអប់រំ យុវជន និងកីឡា", គ្មានថ្ងៃខែ)។ កន្លងមកយើងសង្កេតឃើញថា ដើម្បីពង្រឹងគុណភាព ក្រសួងអប់រំបានធ្វើកំណែទម្រង់លើប្រព័ន្ធអប់រំតាំងពីឆ្នាំ២០១៤ ដោយបានផ្លាស់ប្ដូរភាពអវិជ្ជមានមួយចំនួនមកជាវិជ្ជមាន ក្នុងនោះរួមមាន ការលុបបំបាត់អំពើពុករលួយក្នុងពេលប្រលង និងការលួចចម្លងពេលប្រលង ផ្អែកលើសុភាសិតមួយថា "អ្នកចេះគឺជាប់" ដែលបានបណ្ដុះស្មារតីយុវជនឱ្យខិតខំរៀនសូត្រ។ ជាលទ្ធផលគេឃើញថាមានផ្លែផ្កាគួរឱ្យកត់សម្គាល់ និងកំណែទម្រង់នៅបន្តរហូតមកដល់ពេលបច្ចុប្បន្ន។ ជាក់ស្ដែង ដើម្បីត្រៀមខ្លួនសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤ រដ្ឋមន្ត្រីក្រសួងអប់រំបានដាក់ចេញនូវយុទ្ធសាស្ត្រជាបន្តបន្ទាប់ដូចជា៖ គោលនយោបាយ និងយុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងការអប់រំនៅកម្ពុជា គោលនយោបាយ គោលនយោបាយស្ដីពីការអប់រំបច្ចេកទេស ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ គោលនយោបាយស្ដីពីចក្ខុវិស័យឧត្ដមសិក្សា២០៣០ និងគោលនយោបាយជាតិនានាជាច្រើនទៀត។ ក្រសួងអប់រំ យុវជន និងកីឡាក៏បានរៀបចំផែនការ និងយុទ្ធសាស្ត្រនានារួមមាន បញ្ជ្រាបបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍ឱ្យក្លាយជាឧបករណ៍មួយក្នុងការបង្រៀននិងការរៀន ចែករំលែកចំណេះដឹង និងបំប៉ន សិស្សនិស្សិត លើបំណិន បច្ចេកវិទ្យា និងសារមនាគមន៍ ក៏ដូចជាបង្កើនប្រសិទ្ធភាព និងស័ក្ដិសិទ្ធភាពនៃការរៀននិងបង្រៀន នៅតាមមជ្ឈមណ្ឌលគរុកោសល្យ សាលារៀន គ្រឹះស្ថានអប់រំ ដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សារមនាគមន៍។ ក្រៅពីនេះ ក្រសួងអប់រំបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដើម្បីជំរុញបន្ថែមលើបច្ចេកវិទ្យាថ្មីៗ។ ដើម្បីឱ្យឌីជីថលូបនីយកម្មកាន់តែមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា គប្បីបង្កើនឱកាសដល់និស្សិតដែលកំពុងបន្តការសិក្សា ឱ្យមានឱកាសហាត់ការផ្ទាល់ទាក់

ទងទៅនឹងជំនាញរបស់ខ្លួន ជាពិសេសជំនាញបច្ចេកទេសតែម្តង។ លើសពីនេះ ក្រសួងអប់រំ ក៏គួរពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលដើម្បីឱ្យមានឱកាសចូលរួមបណ្តុះបណ្តាលសិស្សនិស្សិតទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ប្រកបដោយក្រមសីលធម៌ ដើម្បីសម្របខ្លួននឹងបដិវត្តន៍ឧស្សាហកម្មទី៤។ មួយវិញទៀត គឺការជំរុញសិស្សនិស្សិតឱ្យបន្តការសិក្សាទៅក្រៅប្រទេស ដើម្បីក្រេបជញ្ជក់យកចំណេះដឹងមកចែករំលែកដល់សិស្សនិស្សិតជំនាន់ក្រោយ ក៏ដូចជាផ្តល់ឱកាសដល់អ្នកជំនាញគ្រប់ជាតិសាសន៍ចូលមកកម្ពុជាដើម្បីបណ្តុះបណ្តាលសិស្សនិស្សិត ឱ្យកាន់តែមានគុណភាព និងសមត្ថភាពផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យាឌីជីថលកាន់តែខ្លាំងឡើង ហើយអាចប្រកួតប្រជែងលើទីផ្សារអន្តរជាតិ ដោយសារចំណេះដឹងទាក់ទងទៅនឹងបច្ចេកវិទ្យាព័ត៌មាន គឺជាកម្លាំងស្នូលដែលមិនអាចខ្វះបានសម្រាប់ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤។

### ❖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា

ការប្រើប្រាស់គ្រឿងអេឡិចត្រូនិក បានដើរតួនាទីយ៉ាងសំខាន់ក្នុងជីវភាពរស់នៅបច្ចុប្បន្នដូចជា ការទិញនិងលក់ផលិតផលតាមប្រព័ន្ធអនឡាញ ការហៅមធ្យោបាយធ្វើដំណើរតាមកម្មវិធីទូរស័ព្ទ ប្រតិបត្តិការសាច់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកជាដើម។ ជាក់ស្តែងក្រសួងពាណិជ្ជកម្ម បានអនុវត្តការចុះបញ្ជីតាមប្រព័ន្ធអនឡាញ ហើយនឹងគ្រោងដាក់ដំណើរការប្រព័ន្ធត្រួតពិនិត្យ និងការវិវត្តការងារនៅក្នុងក្រសួងផងដែរ។ ដូចនេះ ដើម្បីសម្របខ្លួនទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាទំនើបៗ គឺទាមទារឱ្យរាជរដ្ឋាភិបាល ផ្គត់ផ្គង់នូវគ្រឿងសម្ភារអេឡិចត្រូនិក និងបណ្តុះបណ្តាលការប្រើប្រាស់ទាក់ទងប្រព័ន្ធអេឡិចត្រូនិក។ សំខាន់ជាងនេះ កម្ពុជាគួរបង្កើនការវិនិយោគលើសម្ភារអេឡិចត្រូនិក ឱ្យបានច្រើននិងលឿនបំផុតដោយខ្លួនឯង ដើម្បីឆ្លើយតបទៅនឹងតម្រូវការទំនើបកម្មបច្ចេកវិទ្យាក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ ដូចជាបំពាក់គ្រឿងអេឡិចត្រូនិកតាមគ្រឹះស្ថានសិក្សារដ្ឋនិងឯកជន តាមក្រសួងស្ថាប័នរដ្ឋ ព្រមទាំងជំរុញការបំពាក់ប្រព័ន្ធអ៊ីនធឺណិត ឱ្យបានទូលំទូលាយនៅទូទាំងប្រទេស។ នេះជាការជួយកាត់បន្ថយគម្លាតនៃលទ្ធភាពចូលប្រើប្រាស់និងផ្សារភ្ជាប់បច្ចេកវិទ្យារវាងជនបទ និងទីក្រុង ដើម្បីឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់បានគ្រប់គ្នា។ កម្ពុជាបានរៀបចំនូវយុទ្ធសាស្ត្រ ក្នុងការលើកកម្ពស់អក្ខរកម្មឌីជីថលដូចជា តាមរយៈការបង្កើតកម្មវិធីបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ការអភិវឌ្ឍសហគ្រិនភាព និងប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិស្ថានអំណោយផលដល់ការបង្កើតធុរកិច្ចថ្មីៗ ការជំរុញឌីជីថលូបនីយកម្មក្នុងវិស័យធុរកិច្ច ក៏ដូចជាការបង្កើនយន្តការសហប្រតិបត្តិការសហគ្រិនភាព ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល និងភាពជាដៃគូជាមួយនឹងវិស័យឯកជន។ យ៉ាងណាមិញ ការយល់ដឹងទាក់ទងនឹងការប្រើប្រាស់គ្រឿងអេឡិចត្រូនិក ពុំទាន់មានសមភាពនៅឡើយ ដោយហេតុថាតំបន់ខ្លះមានអ្នកយល់ដឹង និងអាចប្រើប្រាស់ប្រព័ន្ធឌីជីថលបានច្រើន ខណៈតំបន់ខ្លះទៀតខ្វះខាតអ្នកមានចំណេះដឹងពាក់ព័ន្ធនឹងបរិបទឌីជីថល ហើយមិនមានសូម្បីតែលទ្ធភាពចូលប្រើប្រាស់អ៊ីនធឺណិត។ ទាំងនេះជាកត្តានៅពីក្រោយវិសមភាពនៃការអភិវឌ្ឍ ដូចនេះរដ្ឋាភិបាលកម្ពុជាគួរលើកទឹកចិត្តសិស្សនិស្សិត យុវជនស្ម័គ្រចិត្តឱ្យចូលរួម ចែករំលែក ជួយបណ្តុះបណ្តាល ឬសហការជាមួយអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយនូវបញ្ហាប្រឈមនេះ។ សរុបមក ការអភិវឌ្ឍជំនាញ ការអប់រំបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល និងការដាក់បញ្ចូលបច្ចេកវិទ្យាឌីជីថលក្នុងកម្មវិធីសិក្សា និងការបង្កើតយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជនរបស់ដៃគូពាក់ព័ន្ធ សុទ្ធដឹងតែជាកត្តាសំខាន់ដែលរដ្ឋាភិបាល ត្រូវយកចិត្តទុកដាក់ ដើម្បីបង្កើតកម្មវិធីអភិវឌ្ឍន៍ និងបណ្តុះបណ្តាលជំនាញឌីជីថលថ្មីៗ ឱ្យមានភាពបត់បែនទៅនឹងតម្រូវការទីផ្សារការងារក្នុងបរិបទទំនើបកម្មនៃបដិវត្តន៍ឧស្សាហកម្មទី៤ ។

### ❖ ការពង្រឹងធនធានហិរញ្ញវត្ថុ

ធនធានហិរញ្ញវត្ថុ គឺជាកត្តាមួយដែលមិនអាចខ្វះបាន ដើម្បីជំរុញ និងគាំទ្រកម្ពុជាក្នុងការចាប់យកបដិវត្តន៍ឧស្សាហកម្មទី៤ មកប្រើប្រាស់។ ជាក់ស្តែង ក្នុងដំណើរការអនុវត្តន៍យុទ្ធសាស្ត្រ និងគោលនយោបាយអប់រំបែបឌីជីល របស់ក្រសួង

អប់រំ ទាមទារឱ្យមានធានធានហិរញ្ញវត្ថុមួយដ៏រឹងមាំ ដើម្បីគាំទ្រដល់ការប្រើប្រាស់បច្ចេកទេសឌីជីថល និងបំពាក់ប្រព័ន្ធអេឡិចត្រូនិក តាមគ្រឹះស្ថានសិក្សា និងអង្គភាព។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការមួយចំនួនក្នុងការបង្កើនចំណូលដូចជា ការដាក់ចេញច្បាប់ និងបទបញ្ញត្តិទាក់ទងនឹងការប្រមូលពន្ធក្នុងស្រុកឱ្យបានត្រឹមត្រូវតាមការកំណត់ រៀបចំនូវបញ្ជីសូចនាករដោយអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន និងកត់ត្រាឱ្យបានត្រឹមត្រូវតាមមាតិកាថវិកា មាតិកាគណនេយ្យ និងស្របតាមកម្មវិធី អនុកម្មវិធីសកម្មភាព និងចង្កោមសកម្មភាពដែលបានគ្រោងទុក។ ដូចនេះ ដើម្បីបង្កើនចំណូលសម្រាប់ផ្គត់ផ្គង់ និងវិនិយោគលើសម្ភារនិងបច្ចេកទេស សម្រាប់រៀបចំរចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថលនៅកម្ពុជា ទាមទារឱ្យរដ្ឋាភិបាលកម្ពុជារៀបចំបញ្ជីចំណូល និងចំណាយតាមការគ្រោងទុកឱ្យបានសមស្រប។

## យុទ្ធសាស្ត្រនានាដើម្បីឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

ដើម្បីសម្រេចទិសដៅក្នុងការចាប់យក គ្រប់គ្រង ប្រើប្រាស់ និងទាញយកផលប្រយោជន៍ជាអតិបរមាពីបដិវត្តន៍ឧស្សាហកម្មទី៤ ឱ្យអស់ពីលទ្ធភាព និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ វាជាភាពចាំបាច់ក្នុងការរក្សាស្ថេរភាព និងសន្តិភាព ព្រោះបើប្រទេសជាតិគ្មានសុខសន្តិភាព យើងក៏មិនអាចអភិវឌ្ឍខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយ និងយ៉ាងពេញលក្ខណៈក្តាប់ឱកាស និងធ្វើមូលដ្ឋានីយកម្មនៃបដិវត្តន៍ឧស្សាហកម្មទី៤ មកក្នុងបរិបទកម្ពុជាដោយពេញលេញបាននោះដែរ។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលក៏ត្រូវរៀបចំនូវគោលនយោបាយ និងយុទ្ធសាស្ត្រមួយចំនួន ដើម្បីឆ្លើយតបទៅនឹងកាលានុវត្តភាពនៃបដិវត្តន៍ឧស្សាហកម្មទី៤ ក៏ដូចជាប្រមើលមើលពីបញ្ហាប្រឈមនានា ដើម្បីត្រៀមខ្លួនដោះស្រាយ ឆ្លើយតប និងគ្រប់គ្រងបញ្ហាទាំងនោះប្រកបដោយមានប្រសិទ្ធភាពខ្ពស់។ កម្ពុជា គប្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសដែលរីកចម្រើនខ្លាំងផ្នែកវិទ្យាសាស្ត្រទាញយកឱកាសនិងសិក្សាបន្ថែម ដើម្បីយកមកចែករំលែក និងបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋឱ្យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការប្រើប្រាស់ និងគ្រប់គ្រងប្រព័ន្ធការងារតាមបែបឌីជីថល។ ប៉ុន្តែខណៈពេលបដិវត្តន៍ឧស្សាហកម្មទី៤ អាចធ្វើឱ្យជីវិតកាន់តែស្រួល វាក៏អាចធ្វើឱ្យមនុស្សកាន់តែខ្ជិលទៅតាមនោះដែរ។ ដូចនេះ ការទទួលយកបដិវត្តន៍ឧស្សាហកម្មទី៤ វាជារឿងមួយដែលមានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ ប្រសិនបើរាជរដ្ឋាភិបាលចេះចាប់យកឱកាសនេះ និងបណ្តុះបណ្តាលធានធានបន្ថែមទៀតទៅតាមភាពចាំបាច់នៃតម្រូវការជាក់ស្តែង នោះកម្ពុជាអាចនឹងក្លាយជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០ តាមផែនការដែលបានគ្រោងទុកជាក់ជាមិនខាន។ ផ្ទុយទៅវិញ ទោះបីរដ្ឋាភិបាលកម្ពុជាមានផែនការច្បាស់លាស់ក៏ដោយក្តី តែបើខ្វះការចូលរួមពីប្រជាពលរដ្ឋទាំងអស់គ្នា ពិសេសយុវជនកម្ពុជាតែម្តង គឺមិនអាចសម្រេចបាននូវការអភិវឌ្ឍបែបឌីជីថលមួយយ៉ាងពេញលេញ តួយ៉ាងមានសេដ្ឋកិច្ច និងការអប់រំបែបឌីជីថលជាដើម។ ដូចនេះហើយ ដើម្បីត្រៀមខ្លួនយ៉ាងពេញទំហឹងសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤ រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលតួនាទីគន្លឹះ និងភាពចាំបាច់ក្នុងការចាប់យកបដិវត្តន៍ថ្មីនេះ ដើម្បីកសាងមូលដ្ឋានគ្រឹះឌីជីថលសំខាន់ៗ ក្នុងគោលដៅសម្រេចកំណើន នៃចក្ខុវិស័យកម្ពុជា ២០៣០ និង២០៥០ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក៏ដូចជាគោលនយោបាយនានា តាមក្រសួងស្ថាប័នពាក់ព័ន្ធ។ គួរបញ្ជាក់ផងដែរថា កាលពីពេលកន្លងទៅ សម្តេចតេជោនាយករដ្ឋមន្ត្រី បានផ្តល់ជាអនុសាសន៍ដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបង្កើតក្រុមការងាររៀបចំក្របខណ្ឌគោលសេដ្ឋកិច្ចឌីជីថល ក្នុងគោលបំណងចាប់យកកាលានុវត្តភាពពីវិទ្យាសាស្ត្រ និងបច្ចេកទេសសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដោយផ្តោតលើទិដ្ឋភាពធំៗចំនួន៣ គឺ៖

- ទី១៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធឌីជីថល និងការរៀបប្រព័ន្ធចំទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

- ទី២៖ ការបង្កើតថ្នាលឌីជីថល និងការអភិវឌ្ឍប្រព័ន្ធធុរកិច្ចឌីជីថល
- ទី៣៖ ការលើកកម្ពស់ឌីជីថលរូបនីយកម្មរដ្ឋាភិបាលសហគ្រិនភាព និងទិន្នន័យបើកចំហ។

មិនត្រឹមតែប៉ុណ្ណោះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់លើសន្តិសុខឌីជីថល ក៏ដូចជាបង្កើតនូវស្តង់ដារួមផ្សេងៗ ដើម្បីធានាសុវត្ថិភាពបរិយាកាស និងការធ្វើធុរកិច្ចសេដ្ឋកិច្ចឌីជីថលសម្រាប់ចាប់យកឱកាស និងទាញយកអត្ថប្រយោជន៍ដ៏ច្រើនលើសលប់ ដែលអាចទទួលបានពីបដិវត្តន៍ឧស្សាហកម្មទី៤។

## កាលានុវត្តភាព និងបញ្ហាប្រឈមក្នុងបដិវត្តន៍ឧស្សាហកម្មទី៤

អ្វីក៏ដោយតែងមានគុណសម្បត្តិ និងគុណវិបត្តិ។ ជាក់ស្តែងបដិវត្តន៍ឧស្សាហកម្មទី៤ ក៏ដូច្នោះដែរ។ ការចាប់យកឱកាសប្រើប្រាស់ និងទាញយកផលប្រយោជន៍នៃទំនើបកម្មឌីជីថលថ្មីនេះ បានផ្តល់នូវកាលានុវត្តភាព និងបញ្ហាប្រឈមដូចគ្នា។

### ❖ កាលានុវត្តភាព

កម្ពុជាបានត្រៀមលក្ខណៈមួយចំនួនដើម្បីចាប់យកឱកាសជាច្រើន ដែលបានមកពីបដិវត្តន៍ឧស្សាហកម្មទី៤ ដូចជាការហៅតាក់ស៊ីឬមធ្យបាយធ្វើដំណើរ ការទិញនិងលក់ទំនិញ ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក និងការទិញសំបុត្រធ្វើដំណើរតាមអនឡាញ ដែលអាចទទួលបានប្រាក់កម្រៃច្រើនជាងមុន។ បដិវត្តន៍ឧស្សាហកម្មទី៤ នឹងធ្វើឱ្យចំណេញពេលវេលាច្រើន មានន័យថាអ្នកគ្រប់គ្រងសហគ្រាសផលិតកម្មទាំងអស់ ទាំងវិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ គឺមិនចាំបាច់ចំណាយពេលវេលាទៅរកព័ត៌មានទេ គឺគាត់អាចមានព័ត៌មានដោយគ្រាន់តែមានទូរស័ព្ទមួយដែលភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត គឺអាចគ្រប់គ្រងទិន្នន័យទាំងអស់នោះបាន (ភារៈ, ២០១៩)។ ឧទាហរណ៍៖ អ្នកទេសចរ គាត់ចង់ទៅដើរលេងឯណា គឺគាត់គ្រាន់តែមានទូស័ព្ទដៃប្រើ គឺគាត់អាចដឹងថាត្រូវទិញសំបុត្រអស់ប៉ុន្មាន និងជិះរថភ្លើងថ្លៃប៉ុន្មានរួចទៅហើយ។ វិស័យឧស្សាហកម្មដូចគ្នាដែរ នឹងទទួលបានអត្ថប្រយោជន៍ពីបដិវត្តន៍ឧស្សាហកម្មថ្មីនេះកាន់តែខ្ពស់ ព្រោះឧស្សាហកម្មប្រើនូវគ្រឿងម៉ាស៊ីន ជំនួសឱ្យកម្លាំងពលកម្ម ដែលធ្វើឱ្យកត្តាផលិតកម្មចំណាយតិច និងផ្តល់ផលចំណេញច្រើនដល់ម្ចាស់មូលធន និងវិនិយោគិន ដែលជាកត្តាទាក់ទាញអ្នកវិនិយោគមកកាន់តែច្រើន នាំឱ្យប្រទេសមានការរីកចម្រើនឆាប់រហ័សលើគ្រប់វិស័យ និងអាចក្លាយជាប្រទេសមួយដែលមានភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់គ្រឿងអេឡិចត្រូនិក និងបច្ចេកវិទ្យាឌីជីថល។

### ❖ បញ្ហាប្រឈម

ទន្ទឹមនឹងគុណសម្បត្តិ បដិវត្តន៍ឧស្សាហកម្មទី៤ ក៏បានផ្តល់នូវផលអវិជ្ជមានមួយចំនួន ហើយអ្វីដែលជាក់ស្តែងមិនអាចប្រកែកបាននោះ គឺការបាត់បង់ឱកាសការងារមួយចំនួន។ ឧទាហរណ៍ កាលពីមុនគេប្រើមនុស្ស ១០នាក់ តែបន្ទាប់ពីគេប្រើប្រាស់រ៉ូបូតជំនួសកម្លាំងមនុស្ស គេអាចត្រូវការមនុស្សតែ ២ ឬ ៣នាក់ប៉ុណ្ណោះ សម្រាប់បញ្ជាគ្រឿងម៉ាស៊ីន និងត្រួតពិនិត្យដំណើរការផលិតកម្ម (ភារៈ, ២០១៩)។ កម្ពុជាមានគម្លាតក្នុងការប្រើប្រាស់បច្ចេកទេស បើធៀបទៅនឹងប្រទេសដែលមានការរីកចម្រើនខាងវិទ្យាសាស្ត្រ តួយ៉ាងសិង្ហបុរី និងចិនជាដើម ដែលជាការលំបាកដល់ភ្ញៀវទេសចរណ៍ដែលមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងបម្រើបម្រាស់តម្រូវការចាំបាច់ផ្សេងៗសម្រាប់ដំណើរទេសចរណ៍ ដូចជាការទូទាត់សាច់ប្រាក់ ពីព្រោះការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជាមានតិចតួច មិនទាន់រីកដុះដាលដល់គ្រប់ទីកន្លែងដូចប្រទេសពួកគេ។ ម្យ៉ាងទៀត ពាក់ព័ន្ធនឹងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតវិញ វិស័យនេះអាចនឹងរងការគំរាមកំហែងដែលប្រទេសលើពិភពលោកព្រួយបារម្ភយ៉ាងខ្លាំង ព្រោះនៅពេលព័ត៌មានផ្ទាល់ខ្លួន គណនីធនាគារ និងព័ត៌មានផ្សេងៗត្រូវបានបញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាទំនើបៗ វាជាហេតុមួយធ្វើឱ្យជនខិលខូចមួយចំនួនព្យាយាមរកនូវលេខសំងាត់ដើម្បីយកព័ត៌មានទាំងអស់នោះ ទៅបម្រើឱ្យផលប្រយោជន៍របស់ពួកគេ ដូចនេះប្រជាពលរដ្ឋទាំងអស់ដែលមានគណនីផ្ទាល់ខ្លួន

ក្នុងប្រព័ន្ធអ៊ីនធឺណិតត្រូវបង្កើនការប្រុងប្រយ័ត្នខ្ពស់។ បច្ចេកវិទ្យានិងទំនើបកម្មឌីជីថល អាចនឹងជំរុញឱ្យមានសង្គ្រាមតាមប្រព័ន្ធអ៊ីនធឺណិតកើតឡើងនៅថ្ងៃអនាគត ដោយសារប្រទេសជុំវិញពិភពលោកមានការរីកចម្រើនខាងវិទ្យាសាស្ត្រ ព័ត៌មានវិទ្យា និងប្រព័ន្ធអេឡិចត្រូនិកយ៉ាងខ្លាំងក្លា ដែលនាំឱ្យប្រទេសទាំងអស់នោះក្រកួតប្រជែងរកឈ្នះ រកចាញ់រវាងគ្នា និងគ្នា។ ក្នុងការប្រកួតប្រជែងនោះ ពុំមាននរណាម្នាក់ចង់ក្លាយជាអ្នកចាញ់ដែរ ដែលកត្តានេះហើយបណ្ដាលឱ្យសង្គ្រាមតាមប្រព័ន្ធអ៊ីនធឺណឺតកើតឡើង។

## ❖ អនុសាសន៍គោលនយោបាយ

តាមរយៈការពិភាក្សាវែកញែក និងមូលដ្ឋានគ្រឹះខាងលើ កម្ពុជាគួរតែមានការបណ្ដុះបណ្ដាលមន្ត្រីតាមមូលដ្ឋាននានា ដើម្បីផ្ទេរនូវចំណេះដឹងទាំងនេះមកកាន់ប្រជាពលរដ្ឋ និងធ្វើឱ្យការយល់ដឹងទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ កាន់តែទូលំទូលាយឡើង។ លើសពីនេះទៅទៀត កម្ពុជាគួរសហការជាមួយប្រទេសជិតខាង ប្រទេសជាសមាជិកអាស៊ាន ចិន ជប៉ុន និងបណ្ដាប្រទេសក្នុងតំបន់ ដែលជាប្រទេសមានការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា ក្នុងការផ្លាស់ប្ដូរនិស្សិតឱ្យទៅសិក្សាក្រៅប្រទេសផ្លាស់ប្ដូរបទពិសោធន៍ ក៏ដូចជាជំរុញនិងសម្រួលដល់ក្នុងការវិនិយោគសម្ភារអេឡិចត្រូនិក មកផ្គត់ផ្គង់ក្នុងស្រុក។ ជាពិសេស រដ្ឋាភិបាលគួរបង្កើនកិច្ចសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជនបន្ថែមទៀតដើម្បីគាំទ្រដល់ដំណើរការឌីជីថលូបនីយកម្មឱ្យកាន់តែរលូនទៅមុខនៅមួយកម្រិតទៀត។ មួយវិញទៀត កម្ពុជាអាចជំរុញនិងលើកកម្ពស់អក្ខរកម្មឌីជីថល ការផ្សារភ្ជាប់បច្ចេកទេសទៅនឹងកម្មវិធីសិក្សា និងបណ្ដុះចិត្តគំនិតទាក់ទងទៅនឹងសីលធម៌និងគុណធម៌នៃការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានត្រឹមត្រូវ ដែលកត្តាទាំងនេះអាចកាត់ជួយបន្ថយហានិភ័យនៃការលួចយកព័ត៌មានផ្ទាល់ខ្លួន និងការវាយប្រហារពីការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក។ ចំពោះបញ្ហាប្រឈមទាក់ទងនឹងការបាត់បង់ការងារវិញ កម្ពុជាអាចប្រែក្លាយបញ្ហានេះជាឱកាសក្នុងការទាក់ទាញវិនិយោគិនឱ្យមកវិនិយោគកាន់តែ និងគាំទ្រសហគ្រិនអាចក្នុងការបង្កើតអ្វីដែលថ្មី តាមការប្រើប្រាស់បច្ចេកវិទ្យាដើម្បីចំណាយថ្លៃដើមផលិតកម្មតិច ហើយទទួលបានផលិតផលច្រើន ដែលនឹងទាក់ទាញការចាប់អារម្មណ៍នៃការវិនិយោគនិងធ្វើអាជីវកម្មនៅកម្ពុជា។ ទាក់ទងផលប្រយោជន៍យ៉ាងច្រើនលើសលប់របស់បដិវត្តន៍ឧស្សាហកម្មទី៤ កម្ពុជាគួរតែមានបំពាក់នូវប្រព័ន្ធគ្រប់គ្រងទឹកដោយស្វ័យប្រវត្តិ ដើម្បីផ្គត់ផ្គង់ខាងវិស័យកសិកម្ម មានន័យថាប្រព័ន្ធនោះអាចដឹងថាពេលណាត្រូវស្រោចដំណាំ ឬពេលណាអត់ជាដើម។ បន្ថែមពីនេះ កម្ពុជាគួរបង្កើតប្រព័ន្ធដែលមានចងក្រងវិធានច្បាប់ទាំងអស់សម្រាប់ដោះស្រាយរឿងក្ដីនានា ដោយគ្រាន់តែបញ្ចូនករណីនោះវានឹងដោះស្រាយដោយស្វ័យប្រវត្តិបាន។ ចំណែកវិស័យឧស្សាកម្មវិញ វាកាន់តែមានភាពងាយស្រួលជាងមុន ពីព្រោះវិស័យឧស្សាហកម្មមួយចំនួននឹងត្រូវជំនួសដោយដំណើរការគ្រឿងអេឡិចត្រូនិក ដែលអាចបញ្ជាតាមរយៈប្រព័ន្ធអ៊ីនធឺណិតងាយស្រួលក្នុងការគ្រប់គ្រង និងទទួលបានផលចំណេញច្រើន។ ក្រៅពីនេះនៅមានប្រព័ន្ធផ្សេងទៀត ដែលផ្ដល់ភាពងាយស្រួលដល់សង្គមតាមរយៈបដិវត្តន៍ឧស្សាហកម្មថ្មីនេះ។ សម្រាប់ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ក៏អាចធ្វើកំណែទម្រង់ឱ្យកាន់តែមានប្រសិទ្ធិភាពជាងមុន ដោយសារមានវត្តមាននៃបដិវត្តន៍ឧស្សាហកម្មទី៤ ព្រោះទៅថ្ងៃអនាគត រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋនឹងប្រមូលផ្ដុំក្នុងប្រព័ន្ធតែមួយ ដែលផ្ដល់ភាពងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង។

ដូចនេះ ការទទួលយកបដិវត្តន៍ឧស្សាហកម្មទី៤ អាចផ្ដល់នូវឱកាសបានយ៉ាងសម្បូរបែប ដែលអាចផ្លាស់ប្ដូរកម្ពុជាបានយ៉ាងឆាប់រហ័សលើគ្រប់វិស័យទាំងអស់ និងអាចឈានទៅសម្រេចគោលដៅជាប្រទេសដែលចំណូលខ្ពស់ក្នុងខាងមុខឆាប់ៗ និងមានការរីកចម្រើនសេដ្ឋកិច្ចឌីជីថល ដូចបានគ្រោងទុក។

## សេចក្ដីសន្និដ្ឋាន

ក្នុងការទទួលយកនូវបដិវត្តន៍ឧស្សាហកម្មទី៤ កម្ពុជាបានត្រៀមនូវលក្ខណៈជាច្រើន ទាំងការពង្រឹងធនធានមនុស្ស ការវិនិយោគលើប្រព័ន្ធបច្ចេកវិទ្យាទំនើបដើម្បីផ្គត់ផ្គង់សម្ភារនានា សម្រាប់

បដិវត្តន៍ឧស្សាហកម្មទី៤ ក៏ដូចជាការប្រើប្រាស់នូវសម្ភារទាំងនោះ បង្កើតនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីភ្ជាប់នូវទិន្នន័យផ្សេងៗ គ្រប់វិស័យទាំងអស់រួមបញ្ចូលគ្នា(រដ្ឋាភិបាលឌីជីថល បរិស្ថានឌីជីថល សេវាសុខាភិបាលឌីជីថល និងសេវាឌីជីថល ។ល។) ដែលអាចសម្រួលរាល់ទិដ្ឋភាពនៃសកម្មភាពប្រចាំថ្ងៃរបស់ពួកគេបានយ៉ាងងាយស្រួល។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយ និងបទបញ្ញត្តិដើម្បីបញ្ជ្រាបព័ត៌មានអំពីការប្រើប្រាស់ប្រព័ន្ធឌីជីថល និងប្រព័ន្ធអេឡិចត្រូនិកទៅដល់ប្រជាពលរដ្ឋ ភាគីពាក់ព័ន្ធឱ្យដើរទាន់ទៅនឹងការរីកចម្រើនយ៉ាងលឿននៃបច្ចេកវិទ្យាសកលលោក រួមទាំងសម្របខ្លួន ក្ដាប់ឱកាស និងទាញយកផលប្រយោជន៍យ៉ាងលើសលប់ពីបដិវត្តន៍ឧស្សាហកម្មទី៤ ដើម្បីជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ និងអភិវឌ្ឍន៍ប្រទេសឱ្យប្រសើរឡើង ក៏ដូចជាលើកកម្ពស់គុណភាពជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។ ចំពោះការធ្វើឌីជីលូបនីយកម្មក្នុងវិស័យសេវាសាធារណៈវិញ នឹងជួយសម្រាលបន្ទុករបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដោះស្រាយបញ្ហាប្រឈម និងតម្រូវការចាំបាច់ឱ្យទាន់ពេលវេលា និងប្រកបដោយសមភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងគុណសម្បត្តិ គុណវិបត្តិមួយចំនួនក៏បានលេចចេញជារូបរាងនៅតាមនោះ រួមមានផលប៉ះពាល់លើឯកជនភាព និងសុវត្ថិភាព ក៏ដូចជាវិសមភាពនៃការប្រើប្រាស់ និងការអភិវឌ្ឍរវាងក្រុមមនុស្ស និងតំបន់ដែលមានលទ្ធភាពចាប់យកឱកាសនេះ និងក្រុមដែលជួបការលំបាកហើយពុំមានលទ្ធភាពទទួលបានឱកាសនេះ។ យ៉ាងណាក្ដី រាជរដ្ឋាភិបាលបានបានធ្វើកិច្ចសហប្រតិបត្តិការជាមួយ ជប៉ុន ព្រមទាំងក្រុមហ៊ុន Smart City Consortium ដើម្បីបង្កើនសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យានៅកម្ពុជា និងបានបង្កើតប្រព័ន្ធរដ្ឋាភិបាលអេឡិចត្រូនិក ដែលចងក្រងនិងផ្ទុកទិន្នន័យតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិក្នុងរចនាសម្ព័ន្ធតែមួយ ដើម្បីតាមដានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យបានកាន់តែប្រសើរជាងមុន ផ្ដល់សេវាសាធារណៈកាន់តែមានប្រសិទ្ធភាពជាងមុន និងបង្កើនឱ្យមានគុណភាព និងតម្លាភាព ពិសេសអាចដោះស្រាយបញ្ហាផ្សេងៗជូនប្រជាពលរដ្ឋបានយ៉ាងឆាប់រហ័ស៕

## ឯកសារយោង


គោលនយោបាយ និងយុទ្ធសាស្ត្រពីបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារមនាគមន៍ក្នុងវិស័យអប់រំ។ (ឆ្នាំ២០១៨)។.ក្រសួងអប់រំ យុវជន និងកីឡា

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣ ដើម្បីកំណើន បង្កើតការងារ ជានាសមធម៌ និងប្រសិទ្ធិភាពឆ្ពោះទៅប្រទេសមានចំណូលខ្ពស់ឆ្នាំ២០៣០។ (ឆ្នាំ២០១៩)។ រាជរដ្ឋាភិបាលកម្ពុជា។ [https://www.moeys.gov.kh/index.php/kh/policies-and-strategies/3179.html#.Xih2JcgzbIU]។

ទីភ្នាក់ងារជាតិមុខរបរ និងការងារ. (គ្មានថ្ងៃខែ). អំពីក្រសួងអប់រំ យុវជន និងកីឡា។ [http://www.nea.gov.kh/nweb/kh/jobshop/course_s/inst/32995/t_index/2]

ភារៈ, សឿង. (ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩). កម្ពុជា និងបដិវត្តន៍ឧស្សាហកម្មទី៤៖ឱកាស និងការប្រឈម។ [សំឡេងបទសម្ភាសន៍]។ [http://www.rfi.fr/km/daily-event-16-06-2019]។

មុន្នីវិសាល, តាន់.(ឆ្នាំ២០១៩). បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម៤.០)។ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ [http://cd-center.org/fourth-industrial-revolution-industry-4-0/ ]។

មុយគីម, ជា.(ឆ្នាំ២០១៩). អ្វីដែលអ្នកគួរយល់ដឹងអំពីទីក្រុងវៃឆ្លាត។ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ [http://cd-center.org/all-you-need-to-know-about-smart-cities/]។

សុភារ័ត្ន, រ៉ាវី.(ឆ្នាំ២០១៨).តើទិសដៅវិស័យអប់រំកម្ពុជាឆ្លើយតបទៅនឹង គោលដៅអភិវឌ្ឍ២០៣០ឬទេ?មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។ [http://cd-center.org/en/essay-contest-2018-first-place-

winner/?fbclid=IwAR1_hVcNg6_XBraJAT6yyJLYEpFs4Dw_mKkFzYqr4yX2Ks0HvCTPi2cTJWA]។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព៖ កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា២០១៥០។(ឆ្នាំ២០១៦)។ រាជរដ្ឋាភិបាលកម្ពុជា។ [https://pressocm.gov.kh/wp-content/uploads/2018/09/20180907_Rectangular_Strategy_IV_Khmer.pdf]។

Rattanak Sar87. (ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ ២០១៩). ការរលំនៃការអប់រំជាការរលំរបស់ជាតិសាសន៍។ [https://lokbongrattanak2.wordpress.com/2019/09/16/the-reason-why-nation-fail/]

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center
Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.com | (+855) 10 950 456